វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសណែនាំអនុវត្ត/២៨០ ប្រក.សហវ.ទវ/០៣ សីហា ១៩៩៥/

ការងារឯកជន ភាវូបនីយកម្ម សហគ្រាសសាធារណៈ

កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ចាប់ពីពេលនេះទៅត្រូវបានគ្រប់គ្រង ដោយក្របខ័ណ្ឌគតិយុត្តមួយ ដែលមានធាតុដូចតទៅ:

I- បទបញ្ញត្តិទាំងឡាយដែលស្ថិតនៅក្នុង ច្បាប់លេខ ១១នស៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ មាត្រា ៨១ ដល់ ៨៦ នៃច្បាប់នេះ ជាមូលដ្ឋានពេញលក្ខណៈច្បាប់ សំរាប់អនុវត្តកិច្ចប្រតិបត្តិការ ឯកជនភាវូបនីយកម្ម ដែលត្រូវបានកំណត់ដូចតទៅនេះ:

- ប្រភេទទ្រព្យសកម្មភាពសាធារណៈដែលមានលក្ខណៈអាចត្រូវផ្ទេរទៅអោយផ្នែកឯកជន( មាត្រា៨១)
- រចនាសម្ព័ន្ធអន្តរក្រសួងទទួលបន្ទុកការអនុវត្តនីតិវិធីឯកជនភាវូបនីយកម្ម: គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ( មាត្រា៨២)
- ការចាត់ចែងធនធានដែលបានមកពីកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ដោយបង្កើតឡើងនូវគណនី ពិសេសមួយរបស់រតនាគារ ( មាត្រា ៨៣ ដល់៨៦)

II- អនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យដែលបានចាត់តាំងអនុវត្តតាម មាត្រា៨១ នៃច្បាប់លេខ ១១នស៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ គ្រប់គ្រងឆ្នាំ ១៩៩៥ បញ្ជាក់ពីបែបបទអនុវត្តនិងសមិទ្ធិកម្ម នៃកិច្ចប្រតិបត្តិការផ្ទេរសហគ្រាស និងទ្រព្យ សកម្មសាធារណៈផ្សេងទៀតទៅអោយផ្នែកឯកជន។

សារាចរនេះមានកម្មវត្ថុធ្វើអោយឃើញជាក់ស្តែងនូវបទបញ្ញត្តិច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥ ពាក់ព័ន្ធនឹងឯកជនភាវូបនីយកម្មព្រមទាំង អនុក្រឹត្យដែលបានចាត់តាំងអនុវត្តនូវបទបញ្ញត្តិទាំងនេះ។

១- ក្របខ័ណ្ឌឯកជនភាវូបនីយកម្ម

មាត្រា៨១នៃច្បាប់លេខ ១១នស៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ បានកំណត់ទ្រព្យសកម្មសាធារណៈទាំងឡាយដែលជាកម្មសិទ្ធិឬការប្រើប្រាស់អាចធ្វើជាកម្មវត្ថុនៃការផ្ទេរទៅអោយផ្នែកឯកជនទាំងអស់រួមមាន:

ក- សហគ្រាសសាធារណៈ ទោះជាមានសកម្មភាពក្នុងវិស័យណាក៏ដោយ (ឧស្សាហកម្ម.ពាណិជ្ជកម្ម សេវាកម្ម) ឬអាជ្ញាធរអាណាព្យាបាលដែលស្ថិតនៅក្រោមបង្គាប់( ក្រសួងខេត្ត-ក្រុង) ។ ត្រង់ចំណុចនេះ ត្រូវបានចាត់ទុកដូចករណីខាងលើដែរ នូវគ្រឹះស្ថានសាធារណៈ ដែលបានអនុវត្តស្វ័យភាពហិរញ្ញវត្ថុក្នុង សកម្មភាពជំនួញដើម្បីផលិតទ្រព្យសម្បត្តិនិងសេវាកម្មសំរាប់លក់នៅលើទីផ្សារ។

ខ- ភាគកម្មសាធារណៈ: ចំណែកដើមទុនដែលរដ្ឋសមូហភាពសាធារណៈក្នុងស្រុក (ខេត្ត.ក្រុង) និងសហគ្រាសសាធារណៈក្នុងន័យនៃចំណុច "ក" ត្រូវរក្សាទុកក្នុងដើមទុនរបស់ក្រុមហ៊ុនចំរុះ។

ក្រុមហ៊ុនចំរុះគឺជាសហគ្រាសមួយ ដែលមានលក្ខណៈមានលក្ខន្តិកៈគតិយុត្តគ្រប់គ្រងដោយច្បាប់ឯកជន (ច្បាប់ពាណិជ្ជកម្ម ឬអនុវត្តច្បាប់ផ្សេងៗផ្នែកពាណិជ្ជកម្មឬស៊ីវិល) ហើយដើមទុនត្រូវបានធ្វើបរិវិសទាន ព្រមគ្នាដោយឯកជនបុគ្គលឬសាធារណៈបុគ្គលដោយគ្មានទាក់ទងជាមួយនឹងចរិតនិយមភាគច្រើនឬភាគតិចនៃភាគកម្មសាធារណៈឡើយ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

គ- រាល់សកម្មភាពឧស្សាហកម្មឬពាណិជ្ជកម្មដែលធ្វើដោយរដ្ឋបាលសាធារណៈ :

- សកម្មភាពមានចរិតជំនួញដែលរដ្ឋបាលសាធារណៈធ្វើជាបន្ទាប់បន្សំដូចជាការដឹកជញ្ជូនទ្រព្យសំភារៈ ការងារផ្សេងៗ ពាណិជ្ជកម្ម ឧស្សាហកម្មធុនតូច...
- សកម្មភាពជំនួញ ដែលធ្វើដោយអង្គភាពសាធារណៈ តាមរបៀបរដ្ឋបាលពុំមែនស្វយ័តក្នុងផែនការហិរញ្ញវត្ថុៈ គឺករណីទូរគមនាគមន៍ ការគ្រប់គ្រងអាកាសយានដ្ឋានការនេសាទអាជីវកម្មព្រៃឈើទេសចរណ៍។

ឃ- បណ្តាទ្រព្យសកម្មផ្សេងទៀត រួមមានៈ

- ទ្រព្យសកម្មរូបិយ (ដីធ្លី.អាគារ.ឋបនកម្ម.សំភារៈ) ដែលជាកម្មសិទ្ធិរបស់រដ្ឋ របស់សមូហភាពសាធារណៈក្នុងស្រុក ឬរបស់សហគ្រាសសាធារណៈ។ ទ្រព្យសកម្មទាំងនោះអាចត្រូវបានកាត់ផ្តាច់ចេញពីសហគ្រាសក្នុងសកម្មភាព ឬក្នុងការជំរះបញ្ជីឬចេញពីទ្រព្យសម្បត្តិរដ្ឋ។ នីតិវិធីងាយស្រួលមួយអាចអនុវត្តបាន ចំពោះសង្ហារឹមទ្រព្យនិងចំពោះទ្រព្យសកម្មដែលបានកែទម្រង់ និងចំពោះទ្រព្យទាំងឡាយដែលមានតម្លៃ មួយដែលនឹងត្រូវបានកំណត់ ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។
- ទ្រព្យសកម្មអរូបិយ : សម្បទានធ្វើអាជីវកម្មទ្រព្យសម្បត្តិមួយ(កន្លែងយកថ្ម.ស្រទាប់លោហជាតិរ៉ែ.ដី ធ្លី. ត្រពាំងទឹក.ព្រៃឈើ) ឬសកម្មភាពមួយមានឬគ្មានចរិតជាសេវាកម្មសាធារណៈ។
- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាភាគទុនសិទ្ធិ និងចំណែកហ៊ុននៅក្នុងដើមទុន របស់ក្រុមហ៊ុនចំរុះ ដែលបាន កំណត់នៅចំណុច "ខ" ខាងលើ។

ដោយឡែកទ្រព្យសកម្មសាធារណៈដែលពាក់ព័ន្ធនឹងផ្នែកការពារ.សន្តិសុខឬបេតិកភ័ណ្ឌវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជាត្រូវស្ថិតនៅក្រៅការអនុវត្តន៍មាត្រា ៨១ នៃច្បាប់លេខ ១០ នស៩៤ស្តីពីច្បាប់ហិរញ្ញ វត្ថុ១៩៩៥ និងបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៣៨អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥។

២- កម្មវិធីឯកជនភាវូបនីយកម្ម

កម្មវិធីនេះ រួមមានកិច្ចសហប្រតិបត្តិការឯកជនភាវូបនីយកម្មទាំងឡាយ ដែលត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល។ កម្មវិធីនេះត្រូវបានរៀបចំឡើងនៅដើមឆ្នាំនីមួយៗដោយផ្អែកលើសមិទ្ធិកម្មពីឆ្នាំមុន។

កម្មវិធីនេះមានធាតុដូចតទៅ:

- បញ្ជីសហគ្រាសឬសកម្មភាពដែលត្រូវផ្ទេរអោយផ្នែកឯកជន
- ប្រតិទិនបង្ហាញពីសមិទ្ធិកម្មនៃកិច្ចប្រតិបត្តិការ
- យុទ្ធសាស្ត្ររួមនៃការប្រតិបត្តិកម្មវិធី

កម្មវិធីត្រូវបានរៀបចំដោយគណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ លើមូលដ្ឋានសំណើដែលបានធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនិងបណ្តាក្រសួងអាណាព្យាបាលផ្សេងៗទៀត។កម្មវិធីនេះត្រូវបានដាក់ឆ្លងសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

៣-គណៈកម្មាធិការឯកជនភាវូបនីយកម្ម

ក- អំពីសមត្ថកិច្ចៈ

គណៈកម្មាធិការឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ដែលបានបង្កើតដោយមាត្រា ៨២ នៃច្បាប់ លេខ០១១ នស៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុ ១៩៩៥មានសមត្ថកិច្ចដូចតទៅៈ

- រៀបចំទម្រង់កម្មវិធីឯកជនភាវូបនីយកម្ម លើមូលដ្ឋាននៃសំណើធ្វើឡើង ដោយក្រសួងអាណាព្យាបាល។
- ត្រួតពិនិត្យកិច្ចសហប្រតិបត្តិការជាបឋមនៃឯកជនភាវូបនីយកម្ម ជាអាទិ៍ៈ ការវាយតំលៃទ្រព្យសកម្ម ការបញ្ជាក់ពីក្របខ័ណ្ឌ គតិយុត្ត របស់សហគ្រាសការជំរះបំណុល ត្រូវទារ.ត្រូវសងការរៀបចំផែនការកាត់ បន្ថយក្របខ័ណ្ឌក្នុងករណីចាំបាច់។ ការអនុវត្តន៍កិច្ចប្រតិបត្តិការ ទាំងនេះក្រសួងអាណាព្យាបាល ជាអ្នក ទទួលសុខត្រូវ។
- យល់ព្រមលើគំរោងឧបករណ៍គតិយុត្តដែលបានស្នើដោយក្រសួងអាណាព្យាបាល ជាពិសេសសៀវភៅបន្ទុកនិងកិច្ចសន្យាឯកជនភាវូបនីយកម្ម។
- ត្រួតពិនិត្យភាពទៀងទាត់នៃនីតិវិធីឯកជនភាវូបនីយកម្មជាអាទិ៍ការដេញថ្លៃលក្ខ័ខ័ណ្ឌប្រកាសលទ្ធផល ដេញថ្លៃនិងការជ្រើសរើសលទ្ធជន។

ខ- អំពីសមាសភាព

គណៈកម្មាធិការឯកជនភាវូបនីយកម្មត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬអ្នក តំណាងហើយមានសមាសភាពដូចតទៅៈ

- សមាជិកអចិន្ត្រៃយ៍ៈតំណាងគណៈរដ្ឋមន្ត្រី អស់លោកតំណាងក្រសួងផែនការ ក្រសួងឧស្សាហកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងសង្គមកិច្ច ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងកសិកម្ម ក្រសួងយុត្តិធម៌ព្រមទាំងធនាគារជាតិនៃកម្ពុជា។
- សមាជិកត្រូវបានអញ្ជើញ ៖ ក្រសួងអាណាព្យាបាល, ដែលមិនមែនជាសមាជិកអចិន្ត្រៃយ៍ ប្រធានសហគ្រាសដែលមានការពាក់ព័ន្ធ ព្រមទាំងបុគ្គលដទៃទៀតដែលចាំបាច់។

គ- ការប្រព្រឹត្តទៅៈ

គណៈកម្មាធិការឯកជនភាវូបនីយកម្ម មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយរ៉ាប់រងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ភារកិច្ចរបស់លេខាធិការដ្ឋានមានជាអាទិ៍ៈ ការរៀបចំកិច្ចការប្រចាំថ្ងៃរបស់គណៈកម្មាធិការ ការកោះអញ្ជើញចូលរួមប្រជុំ ការទុកដាក់សំណុំឯកសារ ការចងក្រង និង ផ្សព្វផ្សាយនូវរបាយការណ៍ការងាររបស់គណៈកម្មាធិការ ការតាមដានគណនីពិសេសរបស់រតនាគារ សំរាប់កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ការកេណ្ឌប្រមូលមធ្យោបាយមនុស្ស និងសំភារៈចាំបាច់សំរាប់ដំណើរការគណៈកម្មាធិការ។

គណៈកម្មាធិការធ្វើការប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬតាមការស្នើសុំរបស់រដ្ឋមន្ត្រីអាណាព្យាបាលដែលមានការពាក់ព័ន្ធ។

សេចក្តីសំរេចទាំងឡាយស្តីពីឯកជនភាវូបនីយកម្ម( ការបញ្ជាក់តំលៃទ្រព្យសកម្មការយល់ព្រមលើឧបករណ៍គតិយុត្តការជ្រើសរើសលទ្ធជន) ត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមសំណើ របស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

៤- បទបញ្ញានៃនីតិវិធី

ក- សំណុំឯកសាឯកជនភាវូបនីយកម្មៈ

សំណុំឯកសារបច្ចេកទេសនៃឯកជនភាវូបនីយកម្មត្រូវបានរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់អាណាព្យាបាលសហគ្រាស រួចត្រូវដាក់សុំមូលវិចារណ៍ ពីគណៈកម្មាធិការឯកជនភាវូបនីយកម្ម ។ សំណុំ ឯកសាររួមមានៈ

- កំណត់បង្ហាញសហគ្រាសដែលធ្វើអោយឃើញសមាសភាពបេតិកភ័ណ្ឌរបស់វាល័ក្ខខ័ណ្ឌទូទៅនៃសកម្មភាពស្ថានភាពហិរញ្ញវត្ថុ នៅការិយបរិច្ឆេទចុងក្រោយ ទស្សនវិស័យនៃការអភិវឌ្ឍន៍ និងពតិមានចាំបាច់ ផ្សេងៗទៀត ។
- គំនូសបំព្រួញនៃឯកជនភាវូបនីយកម្មដែលបានស្នើឡើង
- ប្រសិនបើចាំបាច់គំរោងសៀវភៅបន្ទុកទៀត

ខ- គំនូសបំព្រួញនៃឯកជនភាវូបនីយកម្ម

គំនូសបំព្រួញចាត់ទុកដូចជារូបមន្ត ដែលបានរក្សាទុកសំរាប់ការផ្ទេរសហគ្រាសឬទ្រព្យសកម្មផ្សេងៗរបស់រដ្ឋទៅអោយផ្នែកឯកជន។ អាជ្ញាបញ្ញាក្នុងវិស័យនេះ គឺជ្រើសរើសរូបមន្តសមស្របដើម្បីសំរេចវត្ថុបំណងរួមនៃកម្មវិធីឯកជនភាវូបនីយកម្មដោយគិតអំពីទំហំរបស់សហគ្រាសអំពីប្រភេទសកម្មភាពព្រមទាំងអំពីការស្នើសុំដែលបានលើកឡើង ដោយលទ្ធជនផ្សេងទៀតទៅអនាគត។ ដូច្នេះគំនូសបំព្រួញទាំងអស់ដែលត្រឹមត្រូវនៃឯកជនភាវូបនីយកម្មអាចជ្រើសរើសដូចតទៅៈ

១- ឯកជនភាវូបនីយកម្មទាំងមូលៈ ដែលតម្រូវអោយផ្ទេរកម្មសិទ្ធិលើទ្រព្យសកម្មទាំងអស់របស់សហ គ្រាសទៅអោយលទ្ធជនដែលបានទទួលយក។

២- ឯកជនភាវូបនីយកម្មជាចំណែកៗ : ដែលស្តែងចេញដោយការអនុម័តដើមទុនសហគ្រាសអោយទៅអ្នកវិនិយោគឯកជន ដែលធានាអោយគេនូវចំណែកមួយរបស់រដ្ឋ អំពីការទទួលខុសត្រូវក្នុងការគ្រប់ គ្រង។

៣- ការជួលៈ ជាអាទិ៍ សំរាប់អាគារ....និងដីធ្លី

៤- សម្បទានៈ គឺផ្តល់អោយអ្នកប្រតិបត្តិការឯកជននូវសិទ្ធិធ្វើអាជីវកម្មលើសកម្មភាពដែលជាទូទៅស្ថិត នៅក្រោមអំណាចសេវាកម្មសាធារណៈ ឬអាជីវកម្មលើធនធានធម្មជាតិរ៉ែ.កសិកម្ម.សមុទ្រ.ទន្លេ....

៥- ការលក់ទ្រព្យសកម្មដាច់ដោយឡែកៈ កាលណាគេមិនអាចធ្វើឯកជនភាវូបនីយកម្មសហគ្រាសមួយបានទេ ព្រោះជាអង្គភាពដែលកំពុងដំណើរការឧបករណ៍រួមផ្សំបេតិកភ័ណ្ឌរបស់វាអាចត្រូវបានលក់ដាច់ ដោយឡែកពីគ្នា។

គ- ការដេញថ្លៃ

ដើម្បីដំណើរការឯកជនភាវូបនីយកម្មទ្រព្យសកម្មសាធារណៈវិធានទូទៅគឺធ្វើការដេញថ្លៃ ការផ្សព្វផ្សាយអោយបានទូលំទូលាយលើកលែងតែកាលណាអនុប្បទានជាប្រយោជន៍ដល់បុគ្គលិក។ ការដេញថ្លៃត្រូវធ្វើ ឡើងក្រោមរូបភាពផ្សេង១: ការដេញថ្លៃជាសាធារណៈការពិគ្រោះដេញថ្លៃដោយមានកិរិតកំណត់ការដេញថ្លៃដោយផ្ទាល់មាត់ជាសាធារណៈ ។ ប៉ុន្តែប្រសិនបើពិនិត្យឃើញថាការអនុវត្តន៍នីតិវិធីនេះមិនសមស្រប ឬបើការដេញថ្លៃត្រូវបានប្រកាសថាឥតបានការកិច្ចដំណើរការនេះត្រូវសំរេចយកតាមវិធីស្រុះស្រួល គ្នា។

* ការដេញថ្លៃត្រូវប្រកាសថាឥតបានការ ក្នុងករណីៈ

- អវត្តមានបេក្ខជន
- តម្លៃដែលបានដាក់ដោយបេក្ខជនមិនសមស្របទៅនឹងលក្ខ័ខ័ណ្ឌដែលបានចែងក្នុងសៀវភៅបន្ទុក

- តម្លៃដេញ ទាបជាងការវាយតម្លៃដំបូង

ការដេញថ្លៃត្រូវបានប្រកាស ដោយគណៈកម្មាធិការឯកជនភាវូបនីយកម្ម

ឃ- សៀវភៅបន្ទុក

កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មត្រូវបានសំរេចលើមូលដ្ឋាននៃសៀវភៅបន្ទុកមួយដែលរៀបចំដោយសហគ្រាសពាក់ព័ន្ធក្រោមការទទួលខុសត្រូវរបស់អាណាព្យាបាលសហគ្រាស ។គំរោងសៀវភៅបន្ទុកត្រូវបានដាក់សុំការយល់ព្រមពីគណៈកម្មាធិការឯកជនភាវូបនីយកម្ម មុននឹងប្រកាសធ្វើការដេញថ្លៃ ឬការសន្យាអំពីនីតិវិធីពិគ្រោះជ្រើសរើសលទ្ធជនជាយថាហេតុ។ រូបភាពនិងការរៀបចំសៀវភៅបន្ទុកត្រូវធ្វើអោយតាមប្រភេទនិងទំហំសហគ្រាសព្រមទាំងទ្រព្យសកម្មផ្សេងៗទៀត របស់រដ្ឋដែលអាចធ្វើជាឯកជនភាវូបនីយកម្មបាន។

សៀវភៅបន្ទុកបញ្ជាក់អំពីល័ក្ខខ័ណ្ឌនៃការផ្ទេរសហគ្រាសទៅអោយឯកជន ហើយជាពិសេសៈ

- គំនូសបំព្រួញនៃឯកជនភាវូបនីយកម្ម ដែលបានកត់ត្រាទុក ( ការលក់ទ្រព្យសម្បត្តិទាំងមូល សម្បទាន កិច្ចសន្យាគ្រប់គ្រងការជួល)
- បញ្ជីលំអិតរូបទ្រព្យនិងអរូបទ្រព្យ ដែលបង្កបង្កើតជាបេតិកភ័ណ្ឌរបស់សហគ្រាស
- បែបបទទូទាត់ទាំងឡាយ
- មូលដ្ឋានហិរញ្ញវត្ថុ និង មុខរបររបស់លទ្ធជន
- ទឹកប្រាក់ និង បែបបទរាំងខ្ទប់នៃប្រាក់កក់ធនាគារ
- ចំនួនពលកម្ម ដែលត្រូវរក្សាទុក
- ក្នុងករណីចាំបាច់ ល័ក្ខខ័ណ្ឌធានាសកម្មភាពនិងការងារវិនិយោគដែលបានចុះកិច្ចសន្យាលើសពីនេះ កាលណាជាសកម្មភាពមួយ ដែលមានចរិតផ្តាច់មុខ ឬ សេវាកម្មសាធារណៈសៀវភៅបន្ទុក ត្រូវបញ្ជាក់ច្បាស់ពីល័ក្ខខ័ណ្ឌនៃសកម្មភាពអាជីវកម្មក្នុងន័យការពារផលប្រយោជន៍រួមព្រមទាំងការគោរពកាតព្វកិច្ចនៃនិរន្តរភាពនៃគុណភាពនិងនៃការកំរិតតម្លៃសេវាកម្មសាធារណៈ។

ង- ការវាយតម្លៃ

សហគ្រាសនិងទ្រព្យសកម្មទាំងឡាយរបស់រដ្ឋត្រូវធ្វើការវាយតម្លៃមុននឹងដាក់អោយធ្វើឯកជនភាវូបនីយកម្ម។

ការវាយតម្លៃនេះត្រូវបានប្រគល់អោយជំនាញការឯករាជ្យ និង ប្រកបដោយគុណសម្បត្តិម្នាក់ដែលតែងតាំងឡើងដោយអាណាព្យាបាលសហគ្រាសក្រោយពីមានការយល់ព្រមពីគណៈកម្មាធិការឯកជនភាវូបនីយកម្ម។ ការទាក់ទងដល់សេចក្តីបញ្ជាក់ និងប្រាក់សគុណអ្នកជំនាញការត្រូវបានកំណត់ដោយក្រសួងអាណាព្យាបាលដោយអនុលោមតាមការណែនាំរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម។

របាយការណ៍វាយតម្លៃត្រូវបានបញ្ជូនផ្ទាល់ទៅប្រធានគណៈកម្មាធិការឯកជនភាវូបនីយកម្ម ដោយដាក់ក្នុងស្រោមសំបុត្រសម្ងាត់រៀបចំដោយអ្នកជំនាញការ។ ការបើកស្រោមសំបុត្រនេះ ត្រូវធ្វើឡើងក្នុង ពេលជាមួយគ្នានឹងការប្រកាសលទ្ធផលដេញថ្លៃ។

ច- ការពិនិត្យលទ្ធផលដេញថ្លៃ

ការបើកស្រោមសំបុត្រនិងការពិនិត្យដេញថ្លៃត្រូវបានប្រព្រឹត្តទៅដោយគណៈកម្មការមួយដែលមានសមាជិកតែងតាំងឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

គណៈកម្មការនេះ មានសមាសភាពដូចតទៅ:

| | |
|---|---|
| - អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| - តំណាងគណៈរដ្ឋមន្ត្រីមួយរូប | សមាជិកអចិន្ត្រៃយ៍ |
| -តំណាងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុមួយរូប | សមាជិកអចិន្ត្រៃយ៍ |
| - តំណាងមួយរូបរបស់ក្រសួងដែលមានការពាក់ព័ន្ធផ្ទាល់នឹងសកម្មភាពសហគ្រាស | សមាជិក |
| - ប្រធានសហគ្រាសពាក់ព័ន្ធនឹងការងារឯកជនភាវូបនីយកម្ម | សមាជិក |

នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធានាអោយមានលេខាធិការដ្ឋានរបស់គណៈ កម្មការដេញថ្លៃ។
លទ្ធផលនៃការដេញថ្លៃត្រូវបានកត់ត្រាទុកក្នុងរបាយការណ៍សម្ងាត់ហើយប្រធានគណៈកម្មការដេញថ្លៃ
ត្រូវដាក់ឆ្លងដោយផ្ទាល់ទៅគណៈកម្មាធិការឯកជនភាវូបនីយកម្ម។

ឆ- ការជ្រើសរើសលទ្ធជន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមសំណើរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម ប្រកាសសេចក្តីសំរេចទាំងឡាយស្តីពីការជ្រើសរើសលទ្ធផលនៃសហគ្រាសមួយរបស់រដ្ឋ ឬទ្រព្យសកម្មសាធារណៈ ផ្សេងៗទៀតដែលអាចធ្វើឯកជនភាវូបនីយកម្មបាន។ ក្នុងករណីដែលសហគ្រាសមានទ្រង់ទ្រាយធំ ឬមានសកម្មភាពពាក់ព័ន្ធនឹងផលប្រយោជន៍ជាកំណត់សំរាប់សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជានោះ សេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសុំការយល់ព្រមជាមុនពីសហនាយករដ្ឋមន្ត្រី។

ជ- ការសំងាត់

កិច្ចការទាំងឡាយនៃកិច្ចប្រតិបត្តិការឯកជនភាវូបនីកម្ម ចាប់ពីការវាយតម្លៃរហូតដល់ការសំរេចកិច្ចសន្យាតម្រូវអោយមានចរិតសម្ងាត់។ ការបញ្ជូនសំណុំឯកសារសំរាប់កិច្ចការនេះ ត្រូវតែមានចរិតសម្ងាត់ដែរ ហើយចំពោះអ្នកធ្វើអន្តរាគមន៍ ទាំងអស់ក្នុងអភិក្រមឯកជនភាវូបនីយកម្មត្រូវអនុលោមតាមចរិត លក្ខណៈនេះដែរ។

ឈ- ការប្រតិបត្តិសេចក្តីសំរេច របស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម

ការទទួលខុសត្រូវក្នុងការប្រតិបត្តិសេចក្តីសំរេច ដែលបានប្រកាសដោយគណៈកម្មាធិការឯកជនភាវូបនីយកម្មក្រសួងអាណាព្យាបាល ជាអ្នកទទួលខុសត្រូវនិងសកម្មភាពដែលពាក់ព័ន្ធ។

ដើម្បីសំរេចកិច្ចការនេះក្រសួងអាណាព្យាបាលត្រូវផ្តល់ពត៌មានទៅគណៈកម្មាធិការឯកជនភាវូបនីយកម្ម អំពីល្បឿននៃការអនុវត្តន៍សេចក្តីសំរេចទាំងឡាយ រួចលើកសំណើទៅគណៈកម្មាធិការនេះ ក្នុងករណីចាំបាច់នូវវិធានការសំខាន់ៗ ដើម្បីជំរះឧបសគ្គដែលអាចរំខានដល់ភាពជាក់ស្តែងនៃសេចក្តីសំរេច។ ជាអាទិ៍ កម្លាំងជំរុញរបស់ក្រសួងអាណាព្យាបាលមានសកម្មភាពដូចតទៅ:

ការរៀបចំការចុះហត្ថលេខាលើកិច្ចសន្យាឯកជនភាវូបនីយកម្ម បែបបទអនុវត្តការផ្ទេរទ្រព្យសកម្មទៅអោយកម្មសិទ្ធិករថ្មីការប្រមូលផល ពីឯកជនភាវូបនីយកម្ម ការតាមដានការអនុវត្តន៍ចំណុចសំខាន់ៗ នៃ សៀវភៅបន្ទុក។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

៥- អត្ថប្រយោជន៏ដែលបានផ្តល់ដល់អ្នកទទួលប្រាក់បៀវត្ស

អ្នកទទួលប្រាក់បៀវត្សក្នុងសកម្មភាពឬក្នុងពេលចូលនិវត្តន៏ត្រូវទទួលអត្ថបទប្រយោជន៏ដោយឡែកកាលណាអ្នកទាំងនោះជាបេក្ខជនសំរាប់លទ្ធកម្មសហគ្រាស ឬទ្រព្យសកម្មមួយផ្នែករបស់គេ។

ទំហំនៃអត្ថប្រយោជន៏នេះ ត្រូវបានកំណត់ដោយសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម។ អត្ថប្រយោជន៏ទាំងនេះអាចមានតាមរូបភាពដូចតទៅ:

១- មានសិទ្ធិជាអាទិភាពទិញសហគ្រាសទាំងមូលឬមួយចំណែកនៃទ្រព្យសកម្មរបស់សហគ្រាស

២- តម្លៃលទ្ធកម្មកាត់បន្ថយមួយ និង ពន្យារយៈពេលទូទាត់

ការផ្តល់អត្ថប្រយោជន៏ទាំងនេះបាន លុះត្រាតែអ្នកទទួលប្រាក់បៀវត្សបានបង្ហាញនូវគំរោងមួយរបស់សហគ្រាសដែលត្រូវធានាការអភិវឌ្ឍន៏ក្នុងកម្មភាពបច្ចុប្បន្ន ឬការផ្លាស់ទ្រង់ទ្រាយមធ្យោបាយផលិតកម្មឡើងវិញដើម្បីធ្វើអាជីវកម្ម សកម្មភាពថ្មី។ អត្ថប្រយោជន៏អាចត្រូវបានលុបចោលវិញ ប្រសិនបើយល់ឃើញថាអ្នកទទួលប្រាក់បៀវត្សបានធ្វើខុសកិច្ចសន្យា ដែលបានយល់ព្រមនៅពេលធ្វើលទ្ធកម្មសហគ្រាស។

៦- ការចូលភាគហ៊ុននៃវិនិយោគិនក្រៅប្រទេស

ការចូលរួមកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ត្រូវបានបើកទូលាយចំពោះវិនិយោគិនក្រៅប្រទេសក្នុងលក្ខ័ខ័ណ្ឌនៃការគោរពបទបញ្ញត្តិច្បាប់រដ្ឋធម្មនុញ្ញច្បាប់ និង បទបញ្ញាផ្សេងៗទៀត ព្រមទាំងបំរើការគ្រប់គ្រង ដើម្បីតម្លើង និង ការធ្វើសកម្មភាពសេដ្ឋកិច្ចដោយជនបរទេស។ ចំពោះបញ្ហានេះកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី ក្នុងក្របខ័ណ្ឌកិច្ចប្រតិបត្តិការមួយនៃឯកជនភាវូបនីយកម្ម ត្រូវបានធ្វើឡើងដោយអនុលោមតាមបទបញ្ញត្តិ ច្បាប់ ចុះថ្ងៃទី0៤ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការងារវិនិយោគ។ មាត្រា ១៦នៃច្បាប់នោះ ចែងល័ក្ខខ័ណ្ឌថា:

- កម្មសិទ្ធិដីធ្លីសំរាប់តម្រូវការរបស់គំរោងវិនិយោគ ត្រូវបានយល់ព្រមតែចំពោះរូបវន្តបុគ្គលនិង ចំពោះអង្គភាពគតិយុត្តដែលមានសញ្ជាតិជាខ្មែរ។ មានន័យថាអង្គភាពគតិយុត្តដែលចាត់ទុកជាសញ្ជាតិជាខ្មែរ កាលណាភាគហ៊ុនចាប់ពី ៥១ភាគរយឡើងទៅនៃដើមទុនសរុបត្រូវបានរក្សាដោយរូបវន្តបុគ្គលនីតិ បុគ្គលដែលមានសញ្ជាតិជាខ្មែរ។
- អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈកិច្ចសន្យាជួលដែលមានរយៈពេលវែងរហូតដល់ ៧0 ឆ្នាំ។

ម្យ៉ាងទៀតកិច្ចប្រតិបត្តិការទាំងឡាយនៃឯកជនភាវូបនីយកម្មនិងជ្រើសយកបាននូវអត្ថប្រយោជន៏ដែលបានគ្រោងទុកដោយច្បាប់ដូចបានចែងខាងលើអំពីការងារវិនិយោគតាមបែបបទនៃច្បាប់នេះ និងអត្ថបទ ក្រោយៗទៀត។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

៧- ការប្រើប្រាស់ចំណូលនៃឯកជនភាវូបនីយកម្ម

ចំណូលទាំងឡាយដែលបានមកពីការងារឯកជនភាវូបនីយកម្ម ត្រូវបានប្រើប្រាស់ដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃមាត្រា៨៣ ទៅ ៨៦ នៃច្បាប់លេខ ១១នស៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥។ កិច្ចប្រតិបត្តិការទាំងឡាយ នៃឯកជនភាវូបនីយកម្មត្រូវបានកត់ត្រាជាចំណូល និង ជាចំណាយនៅក្នុងគណនីដោយឡែកមួយហៅថា "គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ" ដែលត្រូវបានបើកនៅក្នុង រតនាគារជាតិសំរាប់កិច្ចការនេះ។ អាណាប័ករបស់គណនីនេះ គឺរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាម ការឯកភាពពីសហនាយករដ្ឋមន្ត្រី។

ធនធានរបស់គណនីនេះត្រូវបានកើតឡើងដោយចំណូលនៃឯកជនភាវូបនីយកម្ម ដោយការផ្តល់អោយពីថវិកាជាតិ និងដោយចំណូលផ្សេងៗ ទៀតដែលនឹងត្រូវបានចាត់តាំងឡើងដោយអត្ថបទច្បាប់ឬបទបញ្ជា។

ធនធាននេះត្រូវបានប្រើប្រាស់សំរាប់បំពេញ:

- ចំណាយសំរាប់រៀបចំសហគ្រាសដែលបានទុកសំរាប់ធ្វើឯកជនភាវូបនីយកម្ម
- ហិរញ្ញប្បទានដល់កម្មវិធីបញ្ចេញក្របខ័ណ្ឌដែលលើសរបស់សហគ្រាសសាធារណៈ
- ការផ្តល់ទាយជ្ជទានជាដើមទុន សំរាប់ជាគុណប្រយោជន៍សហគ្រាសសាធារណៈ ដែលបានរក្សាទុកក្នុង ផ្នែកឯកជន។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់